វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

# សន្ទេបចក្ខុវិស័យប្រទេសកម្ពុជា*

ឆ្នាំ២០១២ លេខ ០៤

## ការចូលរួមពីវិស័យឯកជនក្នុងការអភិវឌ្ឍសេដ្ឋកិច្ច៖ ការប្រមើលមើលឃើញសម្រាប់តំបន់ និងប្រទេសកម្ពុជា[១]

"ក្នុងពិភពលោកសព្វថ្ងៃ និងក្នុងគ្រប់របបនយោបាយ គេឃើញមានប្រទេសតិចណាស់ដែលអាចរីកចម្រើនទៅមុខបាន ដោយពុំចាំបាច់មានសហគមន៍អាជីវកម្មដ៏សកម្មមួយជាមូលដ្ឋានគ្រឹះ។"

*លោក Anangga W. Roosdiono*

*ប្រធានក្រុមប្រឹក្សាអាជីវកម្មអាស៊ាននៃប្រទេសឥណ្ឌូនេស៊ី*

### វិស័យឯកជនជាកម្លាំងជំរុញកំណើន

ក្នុងពេលកន្លងមក វិស័យឯកជនជាកម្លាំងជំរុញការរីកចម្រើននៅកម្ពុជា។ ការធ្វើសេរីភាវូបនីយកម្មសេដ្ឋកិច្ចប្រទេសកម្ពុជានៅដើមទសវត្សរ៍១៩៩០ បានបើកផ្លូវឲ្យមានការធ្វើវិនិយោគយ៉ាងច្រើនផុសផុលលើដីធ្លី សំណង់ និងរោងចក្រកាត់ដេរ។

ទោះបីក្របខ័ណ្ឌដ៏សាមញ្ញផ្នែកស្ថាប័ន និងច្បាប់ ដែលបានដាក់ចេញក្នុងទសវត្សរ៍១៩៩០ បានផ្តល់ជាក្របខ័ណ្ឌសម្រាប់វិនិយោគឯកជនក្តី ប៉ុន្តែសមត្ថភាពមានកម្រិតក្នុងការពង្រឹងអនុវត្តច្បាប់បានទុកឲ្យទីផ្សារ នៅមានការយកប្រាក់កម្រៃក្រៅផ្លូវការជាច្រើន។ ដោយមូលហេតុនេះ ទោះបីកំណើនមានកម្រិតខ្ពស់ក្តី ក៏វាមានលក្ខណៈមិនស្មើគ្នា គ្មានស្ថិរភាព និងគ្មានសមធម៌ទេ។

ដើម្បីដោះស្រាយបញ្ហាខាងលើ រដ្ឋាភិបាលបានប្រឹងប្រែងកសាងក្នុងទសវត្សរ៍កន្លងមកនេះនូវសមត្ថភាពស្ថាប័នដ៏ចាំបាច់ ដើម្បីជួយឲ្យវិនិយោគឯកជនអាចដំណើរការបានប្រកបដោយសុវត្ថិភាព តម្លាភាព និងមានច្បាប់ទម្លាប់ល្អ។ វិនិយោគផ្ទាល់ពីបរទេសបានស្ទុះឡើងដោយការងារកសាងស្ថាប័នចំគោលដៅល្អទាំងនេះ បានផ្តល់ទំនុកចិត្តដល់វិនិយោគទាំងខ្នាតតូច និងខ្នាតធំ។

បទពិសោធន៍ក្នុងប៉ុន្មានឆ្នាំថ្មីៗ បានបង្ហាញច្បាស់ថា រដ្ឋាភិបាលត្រូវតែធ្វើការរលូនគ្នាល្អជាមួយវិស័យឯកជន បើសិនចង់សម្រេចបានកំណើនប្រកបដោយចីរភាព។ ក្របខ័ណ្ឌច្បាប់ផ្សេងៗ ត្រូវតែសំដៅលើកកម្ពស់ការចូលរួមរបស់វិស័យសាធារណៈ–ឯកជន ដើម្បីឲ្យសកម្មភាពខាងគោលនយោបាយ ជួយបម្រើឲ្យតម្រូវការចាំបាច់ខាងសេដ្ឋកិច្ច ហើយសកម្មភាពសេដ្ឋកិច្ច ក៏ជួយបង្កើនប្រសិទ្ធភាពគោលនយោបាយវិញ ព្រមទាំងអាចកៀរគរវិស័យឯកជន ឲ្យជួយសម្រេចគោលដៅនៃកំណើនចម្រុះវិស័យ មានចីរភាព និងសម្រាប់គ្រប់គ្នា និងសមាហរណកម្មក្នុងតំបន់ទៀតផង។

### បណ្តាញក្នុងតំបន់ និងវិស័យឯកជន

កិច្ចសហប្រតិបត្តិការនៅក្នុងអាស៊ានដ៏រឹងមាំមួយ ផ្តល់នូវឱកាសល្អសម្រាប់អាជីវកម្មក្នុងទូទាំងតំបន់។ ក្នុងពេលជាមួយគ្នា អនាគតនៃតំបន់អាស៊ានដែលមានកំណើនលឿននេះ វាផ្សារភ្ជាប់ជាមួយនឹងផលិតភាពនៃអាជីវកម្មទាំងឡាយ។ ដូច្នេះជាការចាំបាច់ណាស់ ដែលប្រទេសនានាក្នុងតំបន់ត្រូវធ្វើការជាមួយគ្នា ដើម្បីបង្កើតបរិយាកាសខាងស្ថាប័ន និងច្បាប់មួយសម្រាប់ជួយឲ្យវិស័យឯកជនរីកដុះដាលឡើង។

ក្នុងពីរ-បីទសវត្សរ៍កន្លងទៅនេះ តំបន់អាស៊ានបានផ្លាស់ប្តូរយ៉ាងជ្រាលជ្រៅ ពីបរិយាកាសនយោបាយមួយដែលលំបាកស្មុគស្មាញ ទៅជាបរិយាកាសគាំទ្រដល់អាជីវកម្ម ដោយប្រទេសនានាបានចំណាយថវិកាច្រើនពាន់លានដុល្លារ ដើម្បីកែលំអហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងកសាងស្ថាប័ន និងគោលនយោបាយផ្សេងៗ ជួយឲ្យអាជីវកម្មនានារីកដុះដាលឡើង។ ទៅអនាគត និន្នាការតំបន់និយមនឹងកើនឡើងទៀតដោយរដ្ឋនានា នឹងធ្វើការជាមួយគ្នា ដើម្បីលើកស្ទួយមុខមាត់វិស័យឯកជន ឆ្លងតាមការចូលរួមក្នុងទីផ្សារតែមួយនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន។

អាស៊ានបានជួយពង្រឹង និងពង្រីកបណ្តាញផលិតកម្មនិងចែកចាយ បង្កើនប្រសិទ្ធភាព និងបំផុសការច្នៃបង្កើតថ្មី និងពង្រីកទីផ្សារសម្រាប់

---

១ អត្ថបទនេះ ជាសេចក្តីសង្ខេបនៃបទបង្ហាញក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១២ ដោយលោក Anangga W. Roosdiono ប្រធានក្រុមប្រឹក្សាអាជីវកម្មអាស៊ាននៃប្រទេសឥណ្ឌូនេស៊ី លោកកស្រី Sandra D´Amico នាយកគ្រប់គ្រងក្រុមហ៊ុន HR Inc. Cambodia និង អនុប្រធាននៃសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា (CAMFEBA) និង បណ្ឌិត Wayne McCullum ប្រធានផ្នែកអភិវឌ្ឍន៍នៃគម្រោងវិនិយោគកោះសង្ហារ។

តួអង្គនានាក្នុងវិស័យឯកជន ប៉ុន្តែលទ្ធផលទទួលបានមានតិចនៅឡើយ ដោយសារកង្វះការសម្របសម្រួល រវាងបណ្តាប្រទេសជាសមាជិក របៀបរបបការិយាធិបតេយ្យសំពីងសំពោង និងបទបញ្ញត្តិច្បាប់ស្មុគស្មាញជំពាក់ជំពិនគ្នា។

ដើម្បីលុបបំបាត់ឧបសគ្គរាំងភាពតភ្ជាប់គ្នាចុះឡើង កន្លងមកគេបានផ្តោតកម្លាំងប្រឹងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ តម្រឹមរបៀបរបបការិយាធិបតេយ្យឲ្យរលូនគ្នា និងអនុម័តចេញនូវក្របខ័ណ្ឌខាងស្ថាប័ននិងច្បាប់ ដើម្បីបង្កើនឱកាសល្អសម្រាប់សកម្មភាពវិស័យឯកជនផ្ទៃក្នុងតំបន់។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) បានដើរតួជាកាតាលីករជួយកាត់បន្ថយរបាំងរូបវ័ន្ត និងស្ថាប័នផ្សេងៗរវាងទីផ្សារនានា និងបើកទ្វារឲ្យវិស័យអាជីវកម្មមានប្រភពតម្រូវការថ្មីៗទៀត។

ប្រទេសជាច្រើននៅក្នុងតំបន់ ជាពិសេស ម៉ាឡេស៊ី សិង្ហបុរី និង ថៃ ឥឡូវនេះ មានក្រុមហ៊ុនជាច្រើនដែលអាចទាញយកចំណេញពីកំណើនសេដ្ឋកិច្ច និងសមាហរណកម្មក្នុងតំបន់ អាស៊ាន ហើយក្លាយខ្លួនជាក្រុមហ៊ុនពហុជាតិ។ ដោយមានគោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ ប្រទេសឯទៀតនៅក្នុងតំបន់ ក៏អាចដើរតាមគន្លងនេះដែរ។

ប្រសិនបើវិស័យឯកជននៅកម្ពុជា ប្រុងខ្លួនចូលរួមក្នុងក្រុមអាជីវកម្មជាន់ខ្ពស់នៅអាស៊ាននេះ គេត្រូវតែបណ្តុះឲ្យមានការយល់ដឹងកាន់តែប្រសើរពីកម្លាំងប្រកួតប្រជែង និងកម្លាំងប្រៀបធៀបនៃសេដ្ឋកិច្ចរបស់ខ្លួន និងចេះប្រើប្រាស់វា។

ការស្រាវជ្រាវសំខាន់ខ្លាំងណាស់សម្រាប់ជំនះ បញ្ហាកង្វះព័ត៌មានដែលកំពុងកាត់បន្ថយដែនអនុវត្តនៃ គោលនយោបាយជំរុញវិស័យឯកជន។ បណ្តាញសិក្សាអប់រំជាន់ខ្ពស់ និងស្ថាប័នស្រាវជ្រាវផ្សេងៗនៅកម្ពុជា ក៏ត្រូវតែកៀរគរមកដែរ ឲ្យជួយវាយតម្លៃពីឧបសគ្គនានាដែលអាជីវកម្មកម្ពុជាត្រូវប្រឈម ដើម្បីបានប្រើប្រាស់បណ្តាញសេដ្ឋកិច្ចផ្ទៃក្នុងតំបន់ ដោយត្រូវផ្តោតលើបញ្ហាគោលនយោបាយ និងត្រូវប្រើប្រាស់ក្របខ័ណ្ឌវិភាគផ្អែកលើអនុវិស័យ។

យន្តការសម្រាប់បញ្ចូលលទ្ធផលស្រាវជ្រាវ ទៅក្នុងគោលនយោបាយក៏សំខាន់ដូចគ្នាដែរ។ បើសិនអាចបំបាត់បន្ទុកចំណាយផ្សេងៗខាងស្ថាប័នបាន ហើយគោលនយោបាយក៏ឆ្លើយតបនឹងការពិតជាក់ស្តែង គេពិតជាសម្រេចលទ្ធផល ដោយទទួលបានវិស័យឯកជនមួយដែលមានលក្ខណៈត្រៀមស្រេចបាច់ ដើម្បីចាប់យកឱកាសល្អផុសចេញពីភាពតភ្ជាប់គ្នាចុះឡើងនៅក្នុងតំបន់។

ប្រទេសកម្ពុជាកំពុងឈានមុខគេ ក្នុងការច្នៃបង្កើតថ្មីនូវក្របខ័ណ្ឌផ្សេងៗ សម្រាប់កិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈ–ឯកជន ក្នុងគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដែលអាចយកមកប្រើជាវិធីសាស្ត្រអនុវត្តល្អជាងគេនៅក្នុងតំបន់។ គម្រោងស្តារជួសជុលផ្លូវដែកគឺជាឧទាហរណ៍ដ៏ត្រចះមួយ នៃរបៀបវារៈគោលនយោបាយផ្តោតលើតំបន់របស់កម្ពុជា។ គម្រោងនេះមិនគ្រាន់តែផ្តល់ហេដ្ឋារចនាសម្ព័ន្ធសម្រាប់តភ្ជាប់អាជីវកម្មកម្ពុជានានា ទៅនឹងទីផ្សារក្នុងតំបន់ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាឧទាហរណ៍មានជោគជ័យល្អ នៃកិច្ចសហការជាដៃគូរវាងវិស័យសាធារណៈ–ឯកជន ដែលអាចយកទៅចម្លងធ្វើតាមនៅកន្លែងឯទៀតៗក្នុងតំបន់ផងដែរ។

ក្របខ័ណ្ឌនានា ដែលកំណត់កិច្ចសហការជាដៃគូរវាងវិស័យសាធារណៈ–ឯកជននៅកម្ពុជា ត្រូវតែពង្រីកថែម ដើម្បីឲ្យមានកិច្ចសហប្រតិបត្តិការកាន់តែធំឡើងនៅក្នុងតំបន់។ ឧទាហរណ៍ ក្របខ័ណ្ឌស្ថាប័នមានតម្លាភាពល្អមួយដែលគ្របដណ្តប់ទូទាំងតំបន់ សម្រាប់ជួយសម្រួលការចូលរួមរបស់វិស័យសាធារណៈ–ឯកជន នៅក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ គឺអាចប្រើប្រាស់បណ្តាញធំៗបាន ដូច្នេះក៏អាចស្រាវជ្រាវលើក្រុមហ៊ុនបានកាន់តែច្រើនដែរ។ វិធីនេះអាចមានប្រយោជន៍ជាងមុនចំពោះរដ្ឋាភិបាល ហើយក៏ជំរុញឲ្យវិស័យឯកជនបង្កើនប្រសិទ្ធភាពផងដែរ។

ក្រុមប្រឹក្សាអាជីវកម្មអាស៊ាន (ASEAN Business Advisory Council) ដែលត្រូវជួបប្រជុំជាលើកទី១ នៅខែមេសានេះ នឹងផ្តល់ជាវេទិកាដ៏មានតម្លៃមួយ សម្រាប់ដោះស្រាយតម្រូវការរបស់វិស័យឯកជនក្នុងក្របខ័ណ្ឌតំបន់ ហើយទាំងមជ្ឈដ្ឋានអាជីវកម្ម និងរដ្ឋាភិបាលគួរតែចាប់យកគំនិតផ្តួចផ្តើមដ៏សំខាន់នេះ។ វាក៏ជាឱកាសល្អសម្រាប់ជំរុញកិច្ចសហប្រតិបត្តិការក្នុងតំបន់ ព្រមទាំងការសម្របសម្រួលក្នុងបណ្តាញអាជីវកម្មរបស់អាស៊ានដែលកំពុងតែរីកលូតលាស់នេះដែរ។

វិស័យឯកជន ក៏មានប្រសិទ្ធភាពខ្លាំងដើម្បីជំរុញការអភិវឌ្ឍសម្រាប់គ្រប់គ្នាក្នុងទូទាំងតំបន់ដែរ។ ការប្រឹងប្រែងបង្កើតឲ្យមានឱកាសល្អស្មើគ្នាសម្រាប់គ្រប់គ្នា គឺជាបញ្ហាប្រឈមមួយដែលវិស័យឯកជន និងរដ្ឋាភិបាល ត្រូវរួមគ្នាដោះស្រាយ។ លទ្ធភាពរដ្ឋតែងមានកម្រិតក្នុងការដោះស្រាយផ្តល់ការងារ ដូច្នេះនៅទីបំផុត គឺមានតែអាជីវកម្មខ្នាតតូច មធ្យម និងធំទេ ដែលអាចផ្តល់ឲ្យបុគ្គលនានានូវឱកាសរកចិញ្ចឹមជីវិត ហើយសកម្មភាពទាំងអស់នេះនឹងរួមគ្នាជំរុញសេដ្ឋកិច្ចទៅមុខ។

ដើម្បីជួយដល់វិស័យអាជីវកម្មក្នុងកិច្ចប្រឹងប្រែងនេះ ក្របខ័ណ្ឌអាស៊ានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌ ត្រូវបានអនុម័តឡើងក្នុងឆ្នាំ២០១១ ដែលនាំឲ្យមានការបង្កើតកម្មវិធីអនុវត្តជាក់ស្តែងមួយចំនួនសម្រាប់ជួយភ្ញោចគម្លាតអភិវឌ្ឍន៍ និងលើកទឹកចិត្តឲ្យមានការចូលរួមកាន់តែធំទូលាយ ក្នុងដំណើរការធ្វើសមាហរណកម្មអាស៊ាន។

សំខាន់បំផុតចំពោះការអភិវឌ្ឍប្រកបដោយសមធម៌នេះដែរ គឺការពង្រីកឱកាសសេដ្ឋកិច្ចសម្រាប់ គ្រួសារមានចំណូលទាបក្នុងបណ្តាប្រទេសសមាជិកអាស៊ាន។ ដោយឡែកការផ្តល់លទ្ធភាពឲ្យបានប្រើប្រាស់ស្ថាប័នហិរញ្ញវត្ថុ គឺមានសារៈសំខាន់បំផុតសម្រាប់បំផុសឡើងនូវសមត្ថភាពសហគ្រិនដែលមិនទាន់ប្រើប្រាស់។

**រូបភាព ១៖ ឥណទានផ្លូវការ គិតជាភាគរយ នៃ ផសស**




ប្រភព៖ World Development Indicators (2012)

កម្ពុជាមានជោគជ័យជាខ្លាំង ក្នុងការបង្កើនឥណទានផ្លូវការសម្រាប់ប្រជាជនក្នុងសង្គមទាំងមូល ហើយក្នុងនេះសហគ្រាសខ្នាតតូចនិងមធ្យម (SME) បានទទួលអត្ថប្រយោជន៍យ៉ាងច្រើន (រូបភាព ១)។ ប៉ុន្តែ SME នៅជួបបញ្ហាមួយចំនួនដែលកាត់បន្ថយលទ្ធភាពចូលរួមក្នុងទីផ្សារ ជាពិសេសបន្ទុកចំណាយខ្ពស់លើការដឹកជញ្ជូន។ ការចូលរួមបំផុសគំនិតផ្តួចផ្តើមផ្សេងៗក្នុងតំបន់ ពាក់ព័ន្ធនឹងពាណិជ្ជកម្មឆ្លងកាត់ព្រំដែន អាចជួយកាត់បន្ថយបន្ទុកចំណាយបានច្រើនសម្រាប់ SME ហើយតាមនេះជួយបង្កើនកម្លាំងប្រកួតប្រជែងក្នុងតំបន់ និងសមត្ថភាពបង្កើតឱកាសការងារ។

## ការកែតម្រូវភាពមិនស៊ីគ្នារវាងជំនាញដែលមាន និងតម្រូវការក្នុងទីផ្សារពលកម្ម

កំហិតមួយដែលរារាំងកំណើនផលិតភាពវិស័យឯកជន និងធ្វើឲ្យវិស័យនេះមិនអាចជួយជំរុញកំណើនចម្រុះ និងសម្រាប់គ្រប់គ្នា គឺកម្លាំងពលកម្មមានជំនាញមិនគ្រប់គ្រាន់ ឬមិនសមស្រប។ ការផ្តល់ឲ្យជនកម្ពុជានូវជំនាញសមស្រប អាចជួយបង្កើនពិពិធកម្មសេដ្ឋកិច្ច ធ្វើឲ្យវាលែងមានមូលដ្ឋានតូចចង្អៀត ព្រមទាំងបង្កើតឱកាសការងារក្នុងឧស្សាហកម្ម ដូចជា ការកែច្នៃកសិផល កម្មន្តសាលមិនមែនកាត់ដេរ និងក្នុងសេវាកម្មផ្សេងៗ។ វាក៏ជួយបង្កើតឱកាសការងារក្នុងវិស័យឯទៀតៗ ដែលអាចជួយកាត់បន្ថយភាពក្រីក្របានយ៉ាងច្រើន។

កម្លាំងពលកម្មមានជំនាញសមស្រប ក៏ជួយបង្កើនសមត្ថភាពរបស់ឧស្សាហកម្ម និងរដ្ឋាភិបាល ឲ្យអាចឆ្លើយតបបានលឿនចំពោះវិបត្តិផ្សេងៗទៅអនាគតដែរ ហើយរឿងនេះអាចដោះស្រាយបានតាមការបណ្តុះបណ្តាលបន្ថែម ឬការផ្តល់ជំនាញមួយថ្មី។ កម្លាំងពលកម្មសកម្ម និងមានលក្ខណៈទន់ភ្លន់ងាយបត់បែន អាចសម្របខ្លួនបានយ៉ាងលឿនទៅនឹងបរិយាកាសសេដ្ឋកិច្ចដែលប្រែប្រួលចុះឡើង។

ដើម្បីកសាងកម្លាំងពលកម្មមានជំនាញសមស្រប គោលនយោបាយត្រូវមានលក្ខណៈជាក់ស្តែង ហើយឆ្លើយតបនឹងស្ថានភាពសេដ្ឋកិច្ចពិតៗ។ ការផ្តល់ព័ត៌មានគ្មានប្រសិទ្ធភាព អាចបង្កអប្រសិទ្ធភាពក្នុងទីផ្សារពលកម្ម និងជាឫសគល់នៃភាពមិនស៊ីគ្នានាបច្ចុប្បន្ន រវាងតម្រូវការ និងជំនាញដែលមាន។ ដោយឡែក កង្វះយន្តការខាងស្ថាប័នសម្រាប់សម្របសម្រួលការងាររវាងអ្នកកសាងគោលនយោបាយ និងអ្នកដឹកនាំអាជីវកម្ម វាកាត់បន្ថយដល់ប្រសិទ្ធភាពនៃទីផ្សារ។

នាបច្ចុប្បន្ន គេឃើញមានកង្វះខាតជាទូទៅនូវការយល់ដឹងពីទីផ្សារក្នុងចំណោមកម្លាំងពលកម្មកម្ពុជា កង្វះព័ត៌មានសម្រាប់យុវជនឪពុកម្តាយ និងអ្នកស្វែងរកការងារ ហើយនិងចំណងទាក់ទងទន់ខ្សោយ ឬគ្មានសោះ រវាងស្ថាប័នទទួលបន្ទុកសំខាន់ ក្នុងការផ្តល់ជំនាញដ៏ចាំបាច់សម្រាប់ជំរុញកម្លាំងពលកម្មទៅមុខ។

គោលនយោបាយ ក៏គួរផ្តោតលើការបំបាត់បញ្ហាទទួលបានព័ត៌មានមិនដូចគ្នាដែរ។ ឧទាហរណ៍ យន្តការសម្រាប់ផ្តល់បានកាន់តែច្រើននូវឱកាសហាត់ការ ឬធ្វើការយកបទពិសោធន៍ជាក់ស្តែង ដូចជា ទស្សនកិច្ចសិក្សា ជាដើម អាចជួយឲ្យពលករវ័យក្មេងបានផ្សាំខ្លួននឹងជំនាញផ្សេងៗ ហើយងាយរកបានការងារធ្វើ។

ការឆ្លើយតបចំពោះការរំពឹងទុក និងការយល់ឃើញរបស់សមាជិកគ្រួសារដែលជាអ្នកសម្រេចអារកាត់លើការសិក្សាអប់រំ និងការវិនិយោគ

រូបភាព ២៖ គំរូមួយសម្រាប់ប្រព័ន្ធសិក្សាអប់រំនៅកម្ពុជា




ប្រភព៖ បទបង្ហាញរបស់លោកស្រី D´ Amico ក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ថ្ងៃទី១៦ កុម្ភៈ ២០១២។

ធនធានក្នុងបញ្ហានេះ ក៏សំខាន់ណាស់ដែរ ព្រោះជួយជៀសវាងការខ្វះខាតធនធានគ្រួសារដ៏កម្រ ទៅលើការសិក្សាដែលទំនងផ្តល់ប្រាក់ចំណូលតិចទៅអនាគត។

ចំណុចសំខាន់បំផុតមួយនៅក្នុងសហប្រតិបត្តិការ រវាងវិស័យសាធារណៈ–ឯកជន គឺការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ដែលផ្តល់ឲ្យកម្លាំងពលកម្មនូវជំនាញបច្ចេកទេស និងវិជ្ជាជីវៈដ៏ចាំបាច់ ដើម្បីជួយជំរុញ និងធ្វើពិពិធកម្មសេដ្ឋកិច្ចកម្ពុជា ហើយក៏ជាស្ពានសម្រាប់ឲ្យពលករវ័យក្មេងរកបានការងារធ្វើ ព្រោះមានជំនាញដែលនិយោជកត្រូវការ។ ដូច្នេះតម្រូវការរបស់វិស័យឯកជនគួរតែបានគិតបញ្ចូលទៅក្នុងកម្មវិធីសិក្សា TVET ហើយក្របខ័ណ្ឌផ្សេងៗសម្រាប់ជួយសម្រួលកិច្ចសហប្រតិបត្តិការបែបនេះ ក៏គួរបង្កើតឡើងដែរ។

កិច្ចសហការជាដៃគូលើ TVET នេះ អាចផ្តល់ឧត្តមភាពប្រៀបធៀបដ៏ធំមួយឲ្យកម្ពុជានៅក្នុងតំបន់។ ទីតាំងជាយុទ្ធសាស្ត្រនៅចំកណ្តាលអាស៊ាន អាចជួយឲ្យកម្ពុជាទទួលបានមធ្យោបាយបណ្តុះបណ្តាលរបស់អាស៊ានមានគុណភាពកម្រិតពិភពលោក បើសិនចេះប្រើប្រាស់បណ្តាញចំណេះដឹងក្នុងតំបន់យ៉ាងសក្តិសិទ្ធិ។

នាបច្ចុប្បន្ន មានកំហិតជាច្រើនដែលកាត់បន្ថយប្រសិទ្ធភាព TVET ដូចជា បញ្ហាថវិកា កង្វះខាតកន្លែងបង្រៀន គ្រូបង្ហាត់/អ្នកបណ្តុះបណ្តាលមានគុណភាពល្អមានតិចនាក់ និងកង្វះការសម្របសម្រួលឲ្យមានគ្រូបង្ហាត់/អ្នកបណ្តុះបណ្តាលពីវិស័យឯកជនមកជួយបង្រៀន។ ប៉ុន្តែកំហិតធំបំផុត គឺកង្វះសមត្ថភាពអនុវត្ត TVET តាមបែបបទ និងទំហំមួយដែលអាចដោះស្រាយបានពិតៗ នូវបញ្ហាកង្វះជំនាញក្នុងទីផ្សារពលកម្មកម្ពុជា។

នៅក្នុងស្រទាប់ប្រជាជនក៏មានការយល់ឃើញថា TVET មិនសូវមានមុខមានមាត់ទេ និងសម្រាប់តែពួកកម្មករ។ ការយល់ឃើញនេះត្រូវតែកែតម្រូវឲ្យបាន តាមរយៈការឃោសនាផ្សព្វផ្សាយ (សារព័ត៌មាន ទូរទស្សន៍ វិទ្យុ) បទបញ្ញត្តិច្បាប់សមស្រប និងឯកសារបញ្ជាក់គុណភាព។

កំណែទម្រង់ផ្សេងៗសម្រាប់កែតម្រូវស្ថានភាពសព្វថ្ងៃ វាស្មុគស្មាញផង និងបន្ទាន់ផង ហើយក្នុងពេលបច្ចុប្បន្ន រដ្ឋាភិបាលពុំមានសមត្ថភាពអនុវត្តវាទេ។ ដូច្នេះ ជាការសំខាន់ណាស់ដែលត្រូវទាញប្រើប្រាស់នូវ កម្លាំងពលកម្មជាសក្តានុពលរបស់ វិស័យឯកជន។ វិធានការអាចអនុវត្តបាន មានដូចជា កិច្ចសហការជាដៃគូរវាងវិស័យសាធារណៈ–ឯកជន ដើម្បីធ្វើការប្រជុំតុមូលមួយ ស្តីពីការធ្វើសកម្មភាពក្នុងបញ្ហាយុវជន និងការងារនៅកម្ពុជា ជាដើម ដែលសំដៅដោះស្រាយកង្វះខាតជំនាញក្នុងវិស័យសំខាន់ៗ និងមធ្យោបាយច្នៃបង្កើតថ្មីសម្រាប់ឈានទៅមុខទៀត។

កម្មវិធីបណ្តុះបណ្តាលលើការងារជាក់ស្តែង ដែលស្របតាមតម្រូវការ និងផ្តល់ឲ្យយុវជននូវជំនាញផ្សេងៗ សម្រាប់ចូលប្រឡូកក្នុងទីផ្សារការងារសព្វថ្ងៃ ក៏មានខ្លះហើយដែរ ប៉ុន្តែជាការសំខាន់បំផុតដែលត្រូវបញ្ជ្រាប និងពង្រីកកម្មវិធី TVET ល្អៗថែមទៀត ព្រមទាំងដាក់អនុវត្តនីតិវិធីផ្សេងៗ ដើម្បីសម្រេចការងារនេះឲ្យបាន។

កម្មវិធី TVET មិនមែនជាឱសថទិព្វសម្រាប់ដោះស្រាយកង្វះជំនាញនៅកម្ពុជានោះទេ។ ដូចមានបង្ហាញក្នុងរូបភាព ២ ស្រាប់ រដ្ឋាភិបាល ស្ថាប័នសិក្សាអប់រំ និងវិស័យឯកជន ត្រូវតែប្រឹងប្រែងកែលំអលើគ្រប់ទិដ្ឋភាពនៃប្រព័ន្ធសិក្សាអប់រំ តាំងពីថ្នាក់បឋម ដល់ TVET ដល់ឧត្តមសិក្សា ក៏ដូចជាពិនិត្យតាមដានលទ្ធផលការងាររបស់និយោជិត និងធ្វើការបណ្តុះបណ្តាលឡើងវិញតាមការចាំបាច់។ ក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយបែបនេះហើយ ដែលជាមធ្យោបាយសម្រាប់ដោះស្រាយមហិច្ឆតារយៈពេលវែងរបស់រដ្ឋាភិបាល។

## អាជីវកម្មមិនប៉ះពាល់ដល់ចីរភាពបរិស្ថាន

តាមធម្មតាតែងមានការប៉ះប៉ូវគ្នារវាងកំណើនសេដ្ឋកិច្ច និងចីរភាពបរិស្ថាន។ ទោះយ៉ាងនេះក្តី ផលប៉ះពាល់លើបរិស្ថាន អាចកាត់បន្ថយបានច្រើន បើសិនមានការអនុវត្តក្របខ័ណ្ឌសមស្រប។

ព័ត៌មានបានមកពីការស្រាវជ្រាវ អាចផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ក្របខ័ណ្ឌធ្វើអាជីវកម្ម ដោយមិនប៉ះពាល់ដល់ ចីរភាពបរិស្ថាន។ សម្បទានដីសេដ្ឋកិច្ច និងសម្បទានព្រៃឈើ បានផ្តល់ប្រភពដ៏មានតម្លៃនៃវិនិយោគបរទេសសម្រាប់កម្ពុជា។ ទំនិញទទួលបានពីសម្បទានទាំងនេះ ពិសេសកៅស៊ូ បានផ្តល់ឲ្យកម្ពុជានូវប្រាក់ចំណូលយ៉ាងច្រើនពីការនាំចេញ។ ប៉ុន្តែជារឿយៗ ចំការដំណាំបង្កការបាត់បង់ព្រៃឈើ និងខូចខាតបរិស្ថាន ដូច្នេះត្រូវមានការគ្រប់គ្រង និងពិនិត្យតាមដានត្រឹមត្រូវ ដើម្បីកាត់បន្ថយផលអាក្រក់នេះឲ្យបានច្រើនជាអតិបរមា។

វិស័យទេសចរណ៍កំពុងផុសឡើង គឺជាកម្លាំងជំរុញកំណើនដែលមិនបំផ្លិចបំផ្លាញដល់ជម្រកធម្មជាតិផ្សេងៗ។ អាជីវកម្មអេកូទេសចរណ៍មានផលប្រយោជន៍ខាងសេដ្ឋកិច្ចក្នុងការការពារបរិស្ថានធម្មជាតិ ហើយចំណុចនេះ ជាហេតុផលសំខាន់មួយសម្រាប់ទាក់ទាញភ្ញៀវ។ អាជីវកម្មអេកូទេសចរណ៍ថ្មីៗជាច្រើន កំពុងផុសឡើងនៅពាសពេញប្រទេស ជាពិសេស នៅតាមតំបន់ដែលមានការយកចិត្តទុកដាក់ខាងវិទ្យាសាស្ត្រ ដូចជា ជួរភ្នំក្រវាញក្នុងខេត្តកោះកុង និងតំបន់ដាច់ស្រយាលក្នុងខេត្តមណ្ឌលគិរី និងរតនគិរី។ ការកែលំអប្រព័ន្ធផ្លូវតភ្ជាប់ និងដឹកជញ្ជូនក៏បានជួយឲ្យតំបន់ទេសចរណ៍ទាំងនេះស្ទុះឡើងយ៉ាងលឿនដែរ។

កន្លងមកវិស័យឯកជន ក៏សកម្មដែរក្នុងការអភិវឌ្ឍកោះមួយចំនួននៅខាងត្បូងខេត្តព្រះសីហនុ ដោយមានការទទួលខុសត្រូវខ្ពស់ខាងសង្គមកិច្ច និងយកចិត្តទុកដាក់ខ្លាំងលើការការពារបរិស្ថានធម្មជាតិ។

គំរូធ្វើអាជីវកម្មមានការទទួលខុសត្រូវខ្ពស់ ខាងបរិស្ថានបែបនេះ រដ្ឋាភិបាលគួរតែជំរុញឡើង និងផ្តល់ការលើកទឹកចិត្ត ហើយមជ្ឈដ្ឋានខាងសិក្សាស្រាវជ្រាវ ក៏គួរជួយផ្តល់ព័ត៌មានឲ្យដែរ។ ការចូលរួមរបស់វិស័យឯកជនសំខាន់ខ្លាំងណាស់ ក្នុងការបណ្តុះយ៉ាងលឿននូវវប្បធម៌មួយដែលផ្តល់តម្លៃឲ្យបរិស្ថានស្មើគ្នានឹងកំណើនសេដ្ឋកិច្ច៕


**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI)**

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក ✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤

e-mail: cdri@cdri.org.kh, website: http://www.cdri.org.kh